# អារម្ភកថា

ក្នុងឋានៈជាជំនួយការឱ្យអាជ្ញាធរសាធារណៈលើការងារមនុស្សធម៌ដូចបានចែងក្នុង យុទ្ធសាស្ត្រកាកបាទក្រហមកម្ពុជា ២០១១ - ២០២០។ ស្របតាមយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ “**រាជរដ្ឋាភិបាលបន្តលើកស្ទួយស្ថានភាពស្ត្រីដែលជាឆ្អឹងខ្នង នៃសេដ្ឋកិច្ច និងសង្គមជាតិ**” និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (២០១៤ - ២០១៨) ការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់វិស័យ និងកម្មវិធីអភិវឌ្ឍនានា ដើម្បីកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះរបស់ស្ត្រី ជាពិសេសស្ត្រីពិការ ស្ត្រីជាជនជាតិដើមភាគតិច និង ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី យេនឌ័រ និងបម្រែបម្រួល អាកាសធាតុ ស្ត្រីក្នុងវិស័យសាធារណៈនិងនយោបាយ កិច្ចការពារផ្លូវច្បាប់ដល់ស្ត្រី សុខភាព និងការអប់រំសម្រាប់ស្ត្រីនិងក្មេងស្រី។ កាកបាទក្រហមកម្ពុជាត្រូវធានាថា រាល់សកម្មភាពកម្មវិធី និងគម្រោងទាំងអស់ ត្រូវផ្ដល់ផលប្រយោជន៍ស្មើភាពចំពោះបុរស និងស្ត្រី ទៅតាមតម្រូវការខុសៗគ្នា រួមទាំងការផ្ដល់មតិយោបល់ និងការចូលរួមស្មើភាពគ្នារបស់បុរស និងស្ត្រី នៅគ្រប់កម្រិតទាំងអស់ក្នុងសមាគមជាតិ។ កាកបាទក្រហមកម្ពុជាធានាថា មិនមានការរើសអើង និងផ្ដល់ឱកាស ទាក់ទិននឹងអាយុ ពិការភាព ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍)។

កាកបាទក្រហមកម្ពុជា សូមថ្លែងអំណរគុណ សហព័ន្ធអន្តរជាតិកាកបាទក្រហមអឌ្ឍចន្ទក្រហមដែល បានផ្ដល់ថវិកាក្នុងការបោះពុម្ពគោលនយោបាយនេះ សម្រាប់ឱ្យក្រុមប្រតិបត្តិ មន្ត្រី អ្នកស្ម័គ្រចិត្ត និង យុវជន កាកបាទក្រហមកម្ពុជា ក្នុងប្រតិបត្តិការការងារមនុស្សធម៌របស់ខ្លួន។

រាជធានី ភ្នំពេញ ថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១៦

**អគ្គលេខាធិការ**

**ពុំ ចន្ទីនី**

# មាតិកា

ក. សេចក្តីផ្តើម ..... 1

ខ. វិសាលភាព ..... 2

គ. កាតព្វកិច្ច និង ការប្តេជ្ញាចិត្ត ..... 3

ឃ. ការទទួលខុសត្រូវ ..... 7

ង. ការតាមដានពិនិត្យឡើងវិញ ..... 9

ច. ឯកសារយោង ..... 9

A. Introduction ..... 15

B. Scope ..... 16

C. Obligations and Commitments ..... 16

D. Responsibility ..... 19

E. Monitoring and Reviewing ..... 20

F. Reference ..... 20

# គោលនយោបាយ
# ស្តីពី
# យេនឌ័រ និងពិពិធភាព

## ក. សេចក្តីផ្តើម

ដោយមានយុទ្ធសាស្ត្រ ២០១១-២០២០ ជាមគ្គុទ្ទេសក៍ កាកបាទក្រហមកម្ពុជាអនុវត្តសកម្មភាពជាច្រើន ផ្តោតលើការងារសុខភាពស្ត្រី និងកុមារនៅតាមសហគមន៍ ដោយផ្តោតសំខាន់លើការគាំទ្រសុខភាពមាតា ទារក និងជួយដល់កុមារកំព្រាដែលទទួលរងគ្រោះដោយសារមេរោគអេដស៍និងជំងឺ អេដស៍។ លើសពីនេះទៀត កាកបាទក្រហមកម្ពុជា បានធ្វើការងារយេនឌ័រ និងពិពិធភាពជាយូរមកហើយ តាមរយៈកម្មវិធីផ្តល់ជំនួយមនុស្សធម៌ដល់ក្រុមងាយរងគ្រោះ ដូចជាការឧបត្ថម្ភដល់ជនពិការ កុមារកំព្រា ចាស់ជរា អ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ និងស្ត្រីមេម៉ាយជាដើម។

នាពេលកន្លងមក កាកបាទក្រហមកម្ពុជា បានកសាងគោលនយោបាយយេនឌ័រ ដែលបានអនុម័តនៅឆ្នាំ ២០០៣។ គោលនយោបាយយេនឌ័រ និងពិពិធភាព នាពេលបច្ចុប្បន្ននេះ គឺជាលទ្ធផលដែលបានមកពីដំណើរការនៃការពិភាក្សាពិនិត្យឡើងវិញដើម្បីធ្វើបច្ចុប្បន្នភាពគោលនយោបាយយេនឌ័រ ឆ្នាំ ២០០៣ ដោយគិតគូរដាក់បញ្ចូលពិពិធភាពឱ្យបានកាន់តែច្រើន។ ដំណើរការនៃការពិនិត្យឡើងវិញនេះ មានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រី/បុគ្គលិកកាកបាទក្រហមកម្ពុជាទាំងនៅថ្នាក់កណ្តាល និងសាខា។

កាលពីខែធ្នូ ឆ្នាំ២០១៤ ក្នុងអំឡុងពេលបេសកកម្មដើម្បីកំណត់នូវវិសាលភាពយេនឌ័រ និងពិពិធភាព និងបន្ទាប់ពីពិភាក្សាជាមួយថ្នាក់ដឹកនាំកាកបាទក្រហមកម្ពុជា បានឯកភាពគ្នាថា កាកបាទក្រហម កម្ពុជា ត្រូវមានអភិក្រមជាយុទ្ធសាស្ត្រនៃការងារយេនឌ័រ និងពិពិធភាព ដើម្បីជាមគ្គុទ្ទេសក៍ដល់គោលនយោបាយ កម្មវិធី និងឧបករណ៍នានា។ អនុសាសន៍ជាច្រើនត្រូវបានស្នើឡើង ដូចតទៅ៖ កាកបាទក្រហម កម្ពុជា ត្រូវស្វែងរកការគាំទ្រដល់ទស្សនាទានយេនឌ័រ និងពិពិធភាព ឱ្យបានទូលំទូលាយនៅក្នុងសង្គម។ គោលនយោបាយ និងបទប្បញ្ញត្តិដែលមានលក្ខណៈស្តង់ដារស្តីពីយេនឌ័រ និងពិពិធភាព គួរតែធ្វើសមាហរណកម្មទៅក្នុងសកម្មភាពការងាររបស់កាកបាទក្រហមកម្ពុជា។ ក្នុងនាមជាជំនួយការឱ្យអាជ្ញាធរសាធារណៈក្នុងវិស័យមនុស្សធម៌ កាកបាទក្រហមកម្ពុជាគួរតែជំរុញឱ្យមានការគាំទ្រ ការអនុវត្ត និងការលើក កម្ពស់ការផ្សព្វផ្សាយគោលនយោបាយស្តីពីយេនឌ័រ និងពិពិធភាព នៅក្នុងជួរគណៈអភិបាល និង គណៈគ្រប់គ្រង ក៏ដូចជាមន្ត្រី/បុគ្គលិក អ្នកស្ម័គ្រចិត្ត យុវជនកាកបាទក្រហមឱ្យបានកាន់តែទូលំទូលាយ។

## ២. វិសាលភាព

យេនឌ័រ គឺជាភាពខុសគ្នាដែលសង្គមបង្កើតឡើង រវាងបុរស និងស្ត្រី នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ យេនឌ័រកំណត់នូវតួនាទី ការទទួលខុសត្រូវ អំណាចនិងធនធានរបស់បុរស និងស្ត្រី នៅក្នុងវប្បធម៌នីមួយៗ។ ភាពខុសគ្នានៃយេនឌ័រ អាចផ្លាស់ប្តូររៀងរាល់ពេល ហើយភាពខុសគ្នានេះអាចកើតឡើងនៅក្នុងវប្បធម៌តែមួយនិងខុសៗគ្នា។ វិសមភាពយេនឌ័រមានទម្រង់ច្រើនយ៉ាង និងជាឫសគល់នៃទំនាក់ទំនងអំណាចមិនស្មើភាពគ្នា ។វិសមភាពយេនឌ័រ និងការរំលោភអំណាចគឺជាឫសគល់នៃបញ្ហាដែលបង្ករអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ។ អំពើហិង្សាទាក់ទងនឹងផ្លូវភេទនិងយេនឌ័រ គឺជាវាក្យសព្ទដែលគ្របដណ្តប់នូវទង្វើអាចបង្កគ្រោះថ្នាក់ណាមួយ ដែលជាលទ្ធផល ឬភាពទំនងដែលអាចកើតឡើង

បង្កឱ្យមានគ្រោះថ្នាក់ដល់រាងកាយ ផ្លូវភេទ និងផ្លូវចិត្ត ឬបង្កការឈឺចាប់ដល់បុគ្គលទៅលើទំនាក់ទំនងយេនឌ័ររបស់ពួកគេ។ ក្រៅពីនេះរួមមាន អំពើហិង្សាផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ការចាប់បង្ខំឬការឆាប់រៀបអាពាហ៍ពិពាហ៍ ការចាប់បង្ខំឱ្យធ្វើពេស្យាចារ ការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទ និងការបដិសេធនូវធនធាន ឱកាស និងសេវាកម្មនានា៕។

ពិពិធភាព គឺជាភាពខុសគ្នារវាងមនុស្ស ដែលរួមមាន ភាពខុសគ្នារវាងអាយុ ពិការភាព ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍)។

គោលនយោបាយនេះ បង្កើតឡើងនូវមូលដ្ឋានសម្រាប់កាកបាទក្រហមកម្ពុជា ដើម្បីធានាថាភាពខុសគ្នារវាងយេនឌ័រ និងពិពិធភាព ត្រូវបានយកមកពិចារណា និងឆ្លើយតបជាលក្ខណៈប្រព័ន្ធ ទៅនឹងវិស័យស្នូលដូចបានកំណត់នៅក្នុងយុទ្ធសាស្ត្រកាកបាទក្រហមកម្ពុជា ២០១១-២០២០ មានដូចជា ការគ្រប់គ្រងគ្រោះមហន្តរាយ សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍ ការលើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌របស់ចលនា និងការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍធនធាន។

## គ. ភាតព្វកិច្ច និងការប្តេជ្ញាចិត្ត

### សេចក្តីថ្លែង

ទាក់ទិននឹងបញ្ហាយេនឌ័រ និងពិពិធភាព កាកបាទក្រហមកម្ពុជាត្រូវធានាថារាល់សកម្មភាពកម្មវិធី និងគម្រោងទាំងអស់ ត្រូវផ្តល់ផលប្រយោជន៍ស្មើភាពចំពោះបុរស និងស្ត្រី ទៅតាមតម្រូវការខុសៗគ្នា រួមទាំងការផ្តល់មតិយោបល់ និងការចូលរួមស្មើភាពគ្នារបស់បុរស និងស្ត្រី នៅគ្រប់កម្រិតទាំងអស់ក្នុងសមាគមជាតិ។ កាកបាទក្រហមកម្ពុជាធានាថា មិនមានការរើសអើង និងផ្តល់ឱកាស ទាក់ទិននឹងអាយុ ពិការភាព ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវ

ភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍)។

ដើម្បីសម្រេចបាននូវគោលដៅខាងលើនេះ កាកបាទក្រហមកម្ពុជា ប្តេជ្ញាចិត្តអនុវត្តដូចតទៅ ៖

- គ្រោះមហន្តរាយធម្មជាតិ ជម្លោះ អស្ថេរភាពសង្គមនិងនយោបាយ អាចជះឥទ្ធិពលខុសៗគ្នាចំពោះបុរស ស្ត្រី ក្មេងប្រុសនិងក្មេងស្រី ព្រមទាំងបង្កើតឱ្យមានផលប៉ះពាល់ខុសៗគ្នា ទៅលើមនុស្សដែលមានអាយុខុសគ្នា ជនពិការ ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍)។ ភាពប្រទាក់ក្រឡារវាងយេនឌ័រ និងពិពិធភាព ក៏ដូចជាការងារឆ្លើយតបគ្រោះអាសន្ន និងជំនួយមនុស្សធម៌ រយៈពេលខ្លី និងរយៈពេលវែងរបស់កាកបាទក្រហមកម្ពុជា អាចមានផលប៉ះពាល់ខុសៗគ្នា អាស្រ័យលើយេនឌ័ររបស់បុគ្គលម្នាក់ៗ និងទិដ្ឋភាពទូទៅនៃ ពិពិធភាពរបស់ពួកគេ។
- ការធ្វើសមាហរណកម្មទស្សនៈយេនឌ័រ និងពិពិធភាពទៅក្នុងសកម្មភាពការងារកាកបាទក្រហមកម្ពុជាគឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយឆ្ពោះទៅរកការបំពេញអាណត្តិកាកបាទក្រហមកម្ពុជា ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ជនងាយរងគ្រោះបំផុត។
- កាកបាទក្រហមកម្ពុជា ធ្វើប្រតិបត្តិការនៅក្នុងបរិបទវប្បធម៌ចម្រុះ យ៉ាងទូលំទូលាយ ដែលតម្រូវឱ្យទទួលយកនូវអភិក្រមឆ្លើយតបនឹងបញ្ហារសើបផ្នែកវប្បធម៌ ដោយធ្វើការបញ្ជ្រាបទស្សនៈយេនឌ័រ និងពិពិធភាពទៅក្នុងការងារនេះ។

- ការចូលរួមយ៉ាងពេញលេញទាំងបុរសនិងស្ត្រី និងការដាក់បញ្ចូលទាំង អាយុ ពិការភាព ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍) នៅក្នុងគ្រប់សកម្មភាពកាកបាទក្រហមកម្ពុជា មិនត្រឹមតែធានាបាននូវសមភាពយេនឌ័រ និងពិពិធភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការងាររបស់ស្ថាប័នដែរ។
- ទោះបីជាភារកិច្ចចម្បងរបស់កាកបាទក្រហមកម្ពុជា ត្រូវធានាឱ្យបាននូវការឆ្លើយតប យេនឌ័រ និងពិពិធភាពនៅក្នុងសកម្មភាពកម្មវិធី និងគម្រោងដែលមានស្រាប់របស់កាកបាទក្រហមកម្ពុជា តាមរយៈការបញ្ជ្រាបជាលក្ខណៈយុទ្ធសាស្ត្រ និងជាប្រព័ន្ធក៏ដោយ ក៏ចាំបាច់ត្រូវមានការប៉ាន់ប្រមាណនិងការឆ្លើយតប ដែលជួយដល់ក្រុមពិសេសនៃបុរសឬស្ត្រី ដោយផ្អែកលើលទ្ធផលយេនឌ័រ របស់ពួកគេ រួមមាន អាយុ ពិការភាព ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍)។

កាកបាទក្រហមកម្ពុជាធានាថា មានវិធានការជាស្រេច សម្រាប់សុវត្ថិភាព និងការការពារស្ត្រី និងបុរស មន្ត្រី/បុគ្គលិក អ្នកស្ម័គ្រចិត្ត និងយុវជនកាកបាទក្រហម ទាំងអស់ ពីការកេងប្រវ័ញ្ចផ្លូវភេទនិងការរំលោភបំពាន។

ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួន កាកបាទក្រហមកម្ពុជា ត្រូវ៖

- បង្កើតឱ្យមានទម្រង់ការ និងនីតិវិធីនៅក្នុងស្ថាប័ន ដែលធានាថា សេចក្តីត្រូវការរបស់ក្មេងប្រុស ក្មេងស្រី បុរសនិងស្ត្រី ត្រូវបានបំពេញដោយស្មើភាពគ្នា និងមិនមានការរើសអើង ដោយផ្អែកលើអាយុ ពិការភាព ស្ថាន

ភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍) ក្នុងការឆ្លើយតបគ្រោះមហន្តរាយ ការកាត់បន្ថយភាពងាយរងគ្រោះ ការថែទាំសុខភាព និងសេវាកម្មផ្សេងៗទៀត។

- បង្កើតវិធានការដែលធានាថា ភាពងាយរងគ្រោះនិងសមត្ថភាពជាក់លាក់តាមយេនឌ័ររបស់បុរស ស្ត្រី ព្រមទាំងក្រុមជាក់លាក់ ទៅតាមអាយុ ពិការភាព ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍) ត្រូវបានកំណត់ និងដោះស្រាយ ជាលក្ខណៈប្រព័ន្ធ។
- ធានាថា ទិន្នន័យអ្នកទទួលផល ត្រូវបានបែងចែកទៅតាមយេនឌ័រ និងពិពិធភាព **ភេទ និងអាយុ** (តាមស្តង់ដារអប្បបរមា) និងបែងចែកទៅតាមក្រុមជនពិការ និងក្រុមផ្សេងៗ ដែលជាលទ្ធផល នឹងផ្តល់ផលប៉ះពាល់ជាវិជ្ជមានទៅលើគុណភាពសកម្មភាពកម្មវិធីនិងគម្រោង សម្រាប់ការប៉ាន់ប្រមាណសេចក្តីត្រូវការ និងការកសាងផែនការរបស់សកម្មភាពកម្មវិធីគម្រោង ហើយការវិភាគ យេនឌ័រនិងពិពិធភាព ត្រូវបានសមាហរណកម្មយ៉ាងពេញលេញទៅក្នុងការរៀបចំសកម្មភាពកម្មវិធីនិងគម្រោង ការអនុវត្ត ការពិនិត្យ ការវាយតម្លៃ និងរបាយការណ៍។
- រៀបចំយុទ្ធសាស្ត្រសម្រាប់កសាងសមត្ថភាពបញ្ជ្រាបការងារយេនឌ័រ ដែលជាផ្នែកមួយនៃការងារអភិវឌ្ឍស្ថាប័ន ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះវគ្គបណ្តុះបណ្តាលមន្ត្រី/បុគ្គលិកស្តីពីជំនាញវិភាគយេនឌ័រ និងពិពិធភាព។

- ធានាថា យន្តការនៃការពិនិត្យតាមដាន របាយការណ៍ និងគណនេយ្យភាពសម្រាប់សកម្មភាពកម្មវិធីនិងគម្រោង និងលទ្ធផលនៃការបញ្ជ្រាបយេនឌ័រ ត្រូវបានបង្កើតនិងអនុវត្តយ៉ាងសមស្រប។ ការងារនេះរួមបញ្ចូលទាំង ការវាយតម្លៃអំពីការបំពេញការងារ វិភាគអំពីការបែងចែកថវិកានិងធនធាន និងសកម្មភាព ដើម្បីធ្វើឱ្យមានការចូលរួមពេញលេញរបស់បុរសនិងស្ត្រី ដោយឈរលើមូលដ្ឋានស្មើភាពគ្នា និងមានអត្ថន័យគ្រប់គ្រាន់នៅគ្រប់សកម្មភាពរបស់កាកបាទក្រហមគ្រប់កម្រិត ហើយដាក់បញ្ចូលទាំង អាយុ ពិការភាព ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍)។

## ឃ. ការទទួលខុសត្រូវ

គោលការណ៍នេះ អនុវត្តចំពោះ សមាជិកគណៈអភិបាល មន្ត្រី/បុគ្គលិក អ្នកស្ម័គ្រចិត្តនិងយុវជន ដៃគូ, អ្នកដែលកំពុងផ្តល់សេវាកម្ម ចុះកិច្ចសន្យា ឬសហប្រតិបត្តិការជាមួយកាកបាទក្រហមកម្ពុជា។ល។

គណៈគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ មន្ត្រី/បុគ្គលិក អ្នកស្ម័គ្រចិត្ត និងយុវជនកាកបាទក្រហម ទទួលខុសត្រូវដូចតទៅ៖

- បង្កើនការយល់ដឹង និងជំនាញរបស់មន្ត្រី/បុគ្គលិក និងអ្នកស្ម័គ្រចិត្ត យុវជនឱ្យគិតគូរដល់ភាពខុសគ្នានៅក្នុងសង្គមរវាង បុរស ស្ត្រី ក្មេងប្រុស ក្មេងស្រី និងដឹងពីភាពប្រទាក់ក្រឡាគ្នានៃអាយុ ពិការភាព ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំង

ក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍) ពេលរៀបចំ អនុវត្ត ពិនិត្យតាមដាន និង វាយតម្លៃសកម្មភាពកម្មវិធីនិង គម្រោង។

- ធ្វើការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធនូវទម្រង់ការ និងនីតិវិធីរបស់ស្ថាប័ន ដើម្បីវិភាគយេនឌ័រ និងពិពិធភាពទៅតាមកន្លែងដែលសមស្រប ដែលជាផ្នែកមួយនៃការរៀបចំសកម្មភាពកម្មវិធីនិងគម្រោង ឬពង្រឹងប្រព័ន្ធដែលមានស្រាប់។
- ពង្រឹងតុល្យភាពយេនឌ័រ នៅតាមរចនាសម្ព័ន្ធគ្រប់កម្រិតនៅក្នុងស្ថាប័ន ជាពិសេសឱ្យមានការចូលរួមច្រើនពីស្ត្រី និងពិពិធភាព នៃក្រុមជនជាតិដើមភាគតិច ក្នុងការសម្រេចចិត្តនៅគ្រប់កម្រិត។
- ធានាឱ្យមានឱកាសស្មើគ្នារវាងបុរស និងស្ត្រី ក្នុងចំណោមមន្ត្រី/បុគ្គលិក អ្នកស្ម័គ្រចិត្ត យុវជន ក៏ដូចជាជនពិការ និងអ្នករស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ នៅក្នុងលក្ខខណ្ឌនៃការជ្រើសរើស ការដំឡើងឋានៈ ការទទួលផលប្រយោជន៍ ការបណ្តុះបណ្តាល និងលក្ខខណ្ឌនៃការបំពេញការងារ។

គណៈអភិបាល និងគណៈគ្រប់គ្រង របស់កាកបាទក្រហមកម្ពុជា ទទួលខុសត្រូវ ៖

- ធានាថាគ្រប់គោលនយោបាយ ការសម្រេចចិត្ត និងកម្មវិធីគម្រោង គឺបានផ្តោតលើការងារ យេនឌ័រ និងពិពិធភាព តាមរយៈការប៉ាន់ប្រមាណដ៏ច្បាស់លាស់អំពីផលប៉ះពាល់/លទ្ធផល សម្រាប់បុរស ស្ត្រី និងក្រុមមនុស្ស ដែលមានអាយុខុសគ្នា ពិការភាព ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនជាតិភាគតិច និងអន្តោប្រវេសន៍)។

## ឆ. ការតាមដាន និងពិនិត្យឡើងវិញ

ការតាមដាន និងពិនិត្យឡើងវិញ ទៅលើគោលនយោបាយ យេនឌ័រ និង ពិពិធភាព គឺជាការទទួលខុសត្រូវរបស់គណៈអភិបាល គណៈគ្រប់គ្រង មន្ត្រី/បុគ្គលិក អ្នកស្ម័គ្រចិត្ត យុវជនកាកបាទក្រហមកម្ពុជា ជាពិសេសជនបង្គោលយេនឌ័រ និង ពិពិធភាព។

ការពិនិត្យឡើងវិញ ឬការធ្វើបច្ចុប្បន្នកម្មគោលនយោបាយនេះ ត្រូវធ្វើឡើងនៅពេលដែលមានការផ្លាស់ប្តូរបរិបទទូទៅនៅក្នុងកម្រិតជាតិ ឬកម្រិតអន្តរជាតិ និងក្នុងការអនុវត្ត ។

## ជ. ឯកសារយោង៖

គោលនយោបាយនេះបង្កើតឡើងស្របតាមគោលនយោបាយ យេនឌ័រនិង ពិពិធភាព របស់សហពន្ធ័អន្តរជាតិ និងស្របតាមបរិបទជាតិ។

# សទ្ទានុក្រម GLOSSARY

| ពាក្យ ឬកន្សោមពាក្យ | សេចក្តីពន្យល់ |
|---|---|
| គណនេយ្យភាព<br>Accountability | គណនេយ្យភាពក្នុងន័យអភិបាលកិច្ចល្អ មានន័យថា ជាការអនុវត្តតួនាទី និងភារកិច្ច នៅក្នុងដំណើរការ និងអនុវត្តសេចក្តីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេចនិងអនុវត្ត។ |
| តុល្យភាពយេនឌ័រ ឬ សមភាពយេនឌ័រ<br>Gender Balance or gender equality | សូមមើលសេចក្តីពន្យល់ "សមភាពយេនឌ័រ" នៅខាងក្រោម។<br>**សម្គាល់** ៖ មានឯកសារមួយចំនួនសរសេរ "តុល្យភាពយេនឌ័រ" មានន័យខុសគ្នាបន្តិចពី "សមភាពយេនឌ័រ"។ |
| ទស្សនាទាន | គំនិតឬគោលការណ៍ទាក់ទងនឹងអ្វីដែលជាអរូបី។ |
| ទស្សនៈយេនឌ័រ | ការយកចិត្តទុកដាក់ទៅលើរបៀបខុសៗគ្នា ដែលទំនាក់ទំនងរវាងបុរស និងស្ត្រីមានឥទ្ធិពលទៅលើព្រឹត្តិការណ៍ និងដំណើរការខាងសេដ្ឋកិច្ច នយោបាយ សង្គម ច្បាប់ និងវប្បធម៌ និងការទទួលផលប៉ះពាល់ពីបុរស និងស្ត្រី ពីព្រឹត្តការណ៍ និងដំណើរការទាំងនោះ។ |
| ទស្សនៈយេនឌ័រនិង ពិពិធភាព | *សូមមើល ទស្សនៈយេនឌ័រ (នៅខាងលើ) និង ពិពិធភាព (នៅខាងក្រោម)* |
| ទំនោរផ្លូវភេទ (និន្នាការភេទ)<br>Gender orientation | ការពន្យល់អំពីទំនោរផ្លូវភេទ ឱ្យចំអត្ថន័យនោះ គឺពិតជា ពិបាកបន្តិចដោយសារតែទំនោរផ្លូវភេទមានលក្ខណៈខុសៗគ្នាសម្រាប់មនុស្ស ម្នាក់ទៅមនុស្សម្នាក់។ ការយល់អំពីទំនោរផ្លូវភេទរបស់ខ្លួនមានន័យថាអ្នកដឹងអំពីអារម្មណ៍ផ្លូវភេទរបស់ខ្លួនមានភាពទោរទន់ស្រឡាញ់ពេញចិត្តចំពោះអ្នកដទៃ។ មនុស្សម្នាក់ៗមានទំនោរផ្លូវភេទមិនដូចគ្នាទេ ហើយអ្នកត្រូវស្វែងយល់អំពីរឿងនេះដោយខ្លួនឯងថាអ្នកមានទំនោរទៅភេទមួយណា។ ជាទូទៅក្នុងកំឡុងពេលដែលអ្នកស្ថិតក្នុងវ័យជំទង់អ្នកពិតជាចាប់ផ្តើមស្វែងយល់ពី |

| | |
|---|---|
| | ខ្លួនឯងថាអ្នកមានចំណាប់អារម្មណ៍ចំពោះមនុស្សប្រុសឬ មនុស្សស្រី ឬពេញចិត្តទាំងពីរភេទ។ |
| **បរិបទ ឬ បរិការណ៍**<br>Context | មានន័យដូច កាលៈទេសៈ, លក្ខខណ្ឌ, ស្ថានភាពនៃកិច្ចការ, ស្ថានភាព |
| **ប្រសិទ្ធផល**<br>Efficiency | មានន័យថា ជាដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រង ក្នុងការប្រើប្រាស់ ធនធានឱ្យអស់លទ្ធភាពនិងសន្សំសំចៃខ្ពស់ ដើម្បីបង្កើតលទ្ធផល ដែលមានគុណភាពខ្ពស់ បរិមាណច្រើន អាចបម្រើផលប្រយោជន៍ជាអតិបរមា និងបានឆ្លើយតបទៅតម្រូវការពិតរបស់សហគមន៍/សង្គម។ គោលគំនិតនៃប្រសិទ្ធភាពនិងប្រសិទ្ធផលនៅក្នុងបរិបទអភិបាលកិច្ចល្អ ក៏បានបញ្ចូលផងដែរ ចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការការពារបរិស្ថាន។ បរិមាណ +គុណភាព |
| **ប្រសិទ្ធភាព**<br>Effectiveness | កម្រិតនៃការសម្រេចបានលើលទ្ធផលរំពឹងទុក ទិសដៅ និងគោលដៅ ដោយធ្វើការវាយ តម្លៃលើអាំងឌីការទ័រ។ |
| **ពិការភាព**<br>Disability | ជាលក្ខខណ្ឌរាងកាយឬផ្លូវចិត្ត ដែលកម្រិតការធ្វើចលនា (ឬផ្លាស់ទី) ការប្រើវិញ្ញាណ ឬការធ្វើសកម្មភាពរបស់មនុស្សម្នាក់ នៅក្នុងជីវភាពរស់នៅ។ |
| **ពិពិធភាព**<br>Diversity | ជាភាពខុសគ្នារវាងមនុស្ស ដែលរួមមាន ភាពខុសគ្នារវាងអាយុ ពិការភាព ស្ថានភាពរស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ទំនោរផ្លូវភេទ ស្ថានភាពសង្គម-សេដ្ឋកិច្ច សាសនា សញ្ជាតិ និងជនជាតិដើមភាគតិច (រួមទាំងក្រុមជនភាគតិច និងជនអន្តោប្រវេសន៍)។ |
| **ភាពប្រទាក់ក្រឡារវាងយេនឌ័រនិងពិពិធភាព**<br>Intersections between gender and diversity | ជាទំនាក់ទំនងទៅវិញទៅមក រវាងយេនឌ័រនិងពិពិធភាព។ ភាពប្រទាក់ក្រឡា (intersectionality) លើកកម្ពស់ការយល់ដឹងអំពីសុខុមាលភាពមនុស្ស ដែលត្រូវបានបង្កើតឡើង (ដោយអន្តរកម្ម) នៃសង្គមផ្សេងៗគ្នា (ឧ. ពូជសាសន៍/ជាតិពន្ធុ, ទុគ្គតភាព, យេនឌ័រ, វណ្ណៈ, ភេទ, ភូមិសាស្ត្រ, អាយុពិការភាព/សមត្ថភាព, ស្ថានភាពអន្តោប្រវេសន៍, សាសនា)។ |

| | |
|---|---|
| **មគ្គុទេសក៍ ឬ មគ្គុទ្ទេសក៍** | (ន.) (បា.) (ម័ក-គៈទេស) (--សក) អ្នកសម្ដែងផ្លូវ គឺអ្នកនាំផ្លូវ : ធ្វើជាមគ្គុទេសក៍, មានមគ្គុទ្ទេសក៍ ។ |
| **យេនឌ័រ**<br>Gender | ជាភាពខុសគ្នាដែលសង្គមបង្កើតឡើង រវាងបុរស និងស្ត្រី នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ យេនឌ័រកំណត់នូវតួនាទី ការទទួលខុសត្រូវ អំណាច និងធនធានរបស់បុរស និងស្ត្រី នៅក្នុងវប្បធម៌នីមួយៗ។ ភាពខុសគ្នានៃយេនឌ័រ អាចផ្លាស់ប្តូររៀងរាល់ពេល ហើយភាពខុសគ្នានេះអាចកើតឡើងនៅក្នុងវប្បធម៌តែមួយ និងខុសៗគ្នា។ |
| **វិសមភាពយេនឌ័រ**<br>Gender inequality | អ្វីដែលផ្ទុយពី **សមភាពយេនឌ័រ** គឺជា **វិសមភាពយេនឌ័រ** |
| **សមភាពយេនឌ័រ**<br>Gender equality | សមភាពយេនឌ័រ មានន័យថា ស្ត្រី និងបុរស មានសិទ្ធិ និងឱកាសស្មើគ្នានៅគ្រប់វិស័យទាំងអស់ក្នុងជីវិត។ សមភាពយេនឌ័រក៏មានន័យថា មនុស្សទាំងអស់មានសេរីភាពក្នុងការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន និងជ្រើសរើស ដោយគ្មានការដាក់កំហិត ឬដែនកំណត់ ពីសំណាក់តួនាទីផ្នែកយេនឌ័រដ៏តឹងរ៉ឹងនោះឡើយ។ នៅក្នុងសង្គមមួយដែលគោរពសមភាពយេនឌ័រ ភាពខុសគ្នាផ្នែកអាកប្បកិរិយា បំណងប្រាថ្នា និងសេចក្តីត្រូវការរបស់ស្ត្រី និងបុរស ត្រូវបានគេទទួលស្គាល់ ឲ្យតម្លៃ និងផ្តល់ការគាំទ្រ ដោយឈរលើមូលដ្ឋានសមភាពយេនឌ័រ។ |
| **អន្តោប្រវេសន៍**<br>Migration | ការចូលមកខាងក្នុង ។ ការចូលមកក្នុងប្រទេសណាមួយ ដើម្បីតាំងលំនៅជាប្រាកដនៅទីនោះ ដោយឥតត្រឡប់ទៅកាន់ប្រទេសរបស់ខ្លួនវិញ, ដំណើរដែលជនបរទេសចូលមកតាំងលំនៅក្នុងប្រទេស។ |
| **អភិក្រម**<br>Approach | គឺជាវិធី/របៀប/មធ្យោបាយ សម្រាប់ដោះស្រាយអ្វីមួយ។ |
| **អំពើហិង្សាក្នុងគ្រួសារ**<br>Domestic violence | អំពើហិង្សាក្នុងគ្រួសារ គឺជាការរំលោភបំពាន ឬការបង្ខិតបង្ខំផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ (រួមបញ្ចូលទាំងការប្រមាថមាក់ងាយ ការគំរាមកំហែង និងការដាក់ឱ្យនៅឯកោពីគេឯងនៅក្នុងសង្គមផង |

| | |
|---|---|
| | ដែរ) និងការរំលោភបំពាន ខាងផ្នែកជីវភាព សេដ្ឋកិច្ច ពីសំណាក់បុគ្គលម្នាក់ (ឬច្រើននាក់) ដើម្បីត្រួតត្រាទៅលើបុគ្គលផ្សេងៗទៀត ដែលរស់នៅក្រោមដំបូលតែមួយ ឬសមាជិកក្នុងបន្ទុកគ្រួសារ។ |
| **អំពើហិង្សាទាក់ទងនឹងយេនឌ័រ** | អំពើរំលោភបំពានទាំងឡាយទៅលើភេទណាមួយ ដែលគេគិតថាទន់ ខ្សោយជាងខ្លួន ហើយដែលនាំឱ្យមាន ឬក៏ទំនងជានាំឱ្យមានសេចក្ដី អន្តរាយលើរូបរាងកាយ ផ្លូវភេទ ផ្លូវចិត្ត ឬខាងសេដ្ឋកិច្ច ដោយផ្អែកលើយេនឌ័រនៃបុគ្គលណាមួយ។ តាមធម្មតា គឺគេសំដៅលើស្ត្រីនិងកុមារជាអ្នករងគ្រោះ តែក៏អាចជាអំពើហិង្សាលើភេទមួយផ្សេងទៀតដែរ។ អំពើហិង្សានោះរួមមាន ការគំរាមកំហែង ការបង្ខិតបង្ខំ ការដកហូតសេរីភាព ការរំលោភសិទ្ធិក្នុងការធ្វើការងារដើម្បីចិញ្ចឹមជីវិត ការរំលោភផ្លូវភេទ និងផ្លូវចិត្ត ការលបចាប់ ឬក៏បែបផែនណាមួយនៃការបៀតបៀនរំខាន ទោះជាកើតឡើងក្នុងជីវិតឯកជន ឬសាធារណៈក៏ដោយ។ |
| **អំពើហិង្សាផ្លូវភេទ**<br>Sexual violence | អំពើឈ្លានពានទាំងឡាយណា ធ្វើទៅលើផ្លូវភេទ សេរីភាពផ្លូវភេទរបស់បុគ្គលណាម្នាក់ដែលមិនអាចរំលោភបាន រួមមានអំពើផ្សេងទៀត ដែលមានចរិតលក្ខណៈខាងផ្លូវភេទ ពាក់ព័ន្ធទៅលើអនីតិជនដែលធ្វើឱ្យខូចដល់ការអភិវឌ្ឍរាងកាយរបស់គេ។ |

**សម្គាល់** ៖ សេចក្ដីពន្យល់នៃវាក្យសព្ទខាងលើនេះ អាចខុសៗគ្នាពីស្ថាប័ន/អង្គភាពមួយ និងទៅតាមស្ថានភាពជាក់ស្ដែង

# គោលការណ៍គ្រឹះ របស់ ចលនាអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម

## ភាពមនុស្សធម៌ ភាពមិនលំអៀង អព្យាក្រឹតភាព ឯករាជ្យភាព សេវាកម្មស្ម័គ្រចិត្ត ឯកភាព សកលភាព

**Gender and Diversity Policy**

## A. Introduction

Guided by the Cambodian Red Cross 2011-2020 Strategy, CRC conducts various initiatives with a focus on (community-based) women's and children's health, with an emphasis on giving support to mothers, newborns, and assisting orphans vulnerable children with HIV/AIDS. In addition, CRC has a long history of addressing gender and diversity concerns through its Vulnerable Group Assistance program, which provides support to: people with disabilities, orphanages, the elderly, people living with HIV/AIDS and widows.

Cambodian Red Cross previously developed a gender policy, which was enacted in 2003. This current gender and diversity policy is the result of undertaking a consultative review process to update the 2003 gender policy whilst making it more inclusive of diversity considerations. The review process was conducted by CRC senior management and staff from both headquarter and branches.

During a scoping mission in December 2014, after discussing the needs of a strategic gender and diversity approach to guide all policies, programs and tools with CRC senior management, it was agreed that such an approach is needed by CRC. The following recommendations were made: CRC needs to advocate for gender and diversity concepts more broadly in society; a standard Gender and Diversity regulation and policy should be integrated across CRC; as auxiliary to the public authority in humanitarian field, CRC should encourage the endorsement, implementation and promote awareness of the gender and diversity policy within governing and management boards as well as to staff, volunteers and Red Cross youth more widely.

## B. Scope

Gender refers to the socially-constructed differences between females and males throughout their life cycles. Gender determines the roles, responsibilities, power and resources for females and males in any culture. Gender differences can change over time and are different both within and between cultures. Gender inequality takes many forms and is rooted in unequal power relations “Gender inequality and abuse of power is one of the root causes of sexual and gender-based violence (SGBV). SGBV is an umbrella term for any harmful act that results in, or is likely to result in, physical, sexual or psychological harm or suffering to a person on the basis of their gender. This includes but is not limited to sexual violence, domestic violence, trafficking, forced/early marriage, forced prostitution, sexual exploitation and abuse and denial of resources, opportunities and services”.

Diversity refers to the difference between people, including but not limited to, differences in, age, disability, HIV status, sexual orientation, socio-economic status, religion, nationality and ethnic origin (including minority and migrant groups).

This policy establishes the basis for the Cambodian Red Cross to ensure that the gender and diversity differences are taken into account and systematically addressed in relation to core areas as defined in CRC Strategy 2011 - 2020, such as disaster management, health and health care in the community, promotion of the movement’s fundamental principles and humanitarian values, and organizational development and resource development.

## C. Obligations and Commitments

### Statement

With regard to gender and diversity issues, the Cambodian Red Cross is to ensure that all all activities, programmes and projects are benefiting men and women equally according to their different needs and with the input and equal participation of men and women at all

levels within the National Society. Cambodian Red Cross is to ensure non-discriminatory access and opportunities with regards to age, disability, HIV status, sexual orientation, socio-economic status, religion, nationality and ethnic origin (including minority and migrant groups).

The Cambodian Red Cross is committed to taking the necessary steps towards achieving this goal, in particular recognizing that:

- Natural disasters, conflicts, social and political instability may affect men, women, boys and girls differently, as well as creating differential impacts on people of different ages, people with disability, HIV status, sexual orientation, socio-economic status, religion, nationality and ethnic origin (including minority and migrant groups). That the intersections between gender and diversity, as well as the Cambodian Red Cross emergency response short and long-term humanitarian assistance may also have a different impact depending on a person’s gender and aspects of their diversity;
- The integration of gender and diversity perspective into Cambodian Red Cross action is an important strategy towards the fulfilment of the Cambodian Red Cross mandate to improve the lives of the most vulnerable;
- The Cambodian Red Cross operates in a wide variety of cultures; as such it needs to take a culturally sensitive approach with regard to mainstreaming gender and diversity perspective in Cambodian Red Cross work
- The full participation of both men and women, and being inclusive of age, disability status, HIV status, sexual orientation, socio-economic status, religion, nationality and ethnic origin (including minority and migrant groups) in all Red Cross actions not only ensures gender and diversity equality but also increases the efficiency and effectiveness of the work of the organization;

- Although the primary task of Cambodian Red Cross is to ensure gender sensitivity and diversity in their existing programmes through strategic and systematic mainstreaming, it is also important to assess and respond when necessary and relevant to implement projects that assist special groups of men or women, as a result of their gender, age, disability status, HIV status, sexual orientation, socio-economic status, religion, nationality and ethnic origin (including minority and migrant groups) if situations so require.

Cambodia Red Cross will ensure measures are in place for the safety and protection of all women and men, staff, volunteers and youth from sexual exploitation and abuse.

**To achieve its goal, The Cambodian Red Cross shall:**

- Put in place institutional procedures which ensure that the needs of boys, girls, men and women, are all met equitably and are non-discriminatory based on age, disability status, HIV status, sexual orientation, socio-economic status, religion, nationality and ethnic origin (including minority and migrant groups) in disaster response, vulnerability reduction and the provision of health and other services;
- Formulate measures to ensure that gender-specific vulnerabilities and capacities of men, women, as well as those specific to age, disability status, HIV status, sexual orientation, socio-economic status, religion, nationality and ethnic origin (including minority and migrant groups) are systematically identified and addressed;
- Ensure that data on beneficiaries is disaggregated by gender and diversity **sex and age** (as a minimum standard) and where relevant disaggregate by disability and other groups – where results will have a positive impact on the quality of programmes for needs assessment and programme planning

and that gender and diversity analysis is fully integrated into programme design, delivery, monitoring and evaluation and reporting;

- Design strategies for capacity building in gender mainstreaming as part of institutional development programmes with special attention to staff training on gender and diversity analysis skills;
- Ensure that monitoring, reporting and accountability mechanisms for activities and results in gender mainstreaming are put in place. This includes performance evaluations, budget and resource allocation analysis and actions to enable the full participation of men and women on an equal and meaningful basis in all Red Cross activities at all levels, and being inclusive of age, disability, HIV status, sexual orientation, socio-economic status, religion, nationality and ethnic origin.

**D. Responsibility**

**This policy applies to** all those who work as board members, staff, volunteers and youth in CRC; partners to CRC; those providing services, contracted by or collaborating with CRC **…**

The senior management, staff, volunteers and Red Cross youth is responsible for:

- Increasing awareness and skills of staff, volunteers and youth in considering the social differences between men, women, boys and girls, and understanding the intersections with age, disability, HIV status, sexual orientation, socio-economic status, religion, nationality and ethnic origin when designing, implementing, monitoring and evaluating programmes;
- Conducting a systematic review of the institution's procedures to put in place gender and diversity analysis as part of programming or improving the existing systems;

- Re-enabling a gender balance in the different levels of the structure within their organization, in particular to involve more women and diversity in ethnic origin in the decision-making processes at all levels;
- Ensure equal opportunities among female, male, staff members, volunteers, and youth as well as people with disability and HIV status, in the areas of recruitment, promotion, benefits, training and working conditions.

The governing and management boards of the Cambodian Red Cross are responsible for:

- Eensure all Red Cross policies, decisions and programmes are gender and diversity sensitive through a comprehensive assessment of the impacts/results for men, women, and people of different age groups, disability status, HIV status, sexual orientation, socio-economic status, religion, nationality and ethnic origin.

## E. Monitoring and Reviewing

Monitoring the application of the Gender and Diversity policy is the responsibility of those who work as governing and management boards as well as staff, volunteers and Red Cross youth, in particular the National Society’s Gender and Diversity focal persons,

The review and/ or an update of the present policy will be necessary whenever there is change in general context, nationally or internationally, in practical application.

## F. Reference

This policy is created align to IFRC’s Gender and Diversity policy and based on the national context.

# Fundamental Principles of the International Red Cross Red Cresent Movement

## Humanity Impartiality Neutrality Independence Voluntary Service Unity Universality

